# អំពើហិង្សាយេនឌ័រនៅក្នុងសហគមន៍ផ្ទះជួលនៅភ្នំពេញ

## ការរកឃើញពីការសិក្សាស្រាវជ្រាវដោយ អង្គការក្លាហាន អង្គការភីន និង អង្គការអសក ខែកុម្ភៈ ឆ្នាំ២០១៩

សលាកបត្រព័ត៌មាន ៤/៤

### តើស្ត្រីគួរតែត្រូវស្តីបន្ទោសទេនៅពេលដែលប្តីរបស់ពួកគេប្រើអំពើហិង្សាទៅលើពួកគេ?




### តើស្ត្រីគួរតែត្រូវស្តីបន្ទោសទេនៅពេលដែលជនចម្លែកប្រើអំពើហិង្សាទៅលើពួកគេ?




### តើស្ត្រីត្រូវបានគេស្តីបន្ទោសចំពោះអំពើហឹង្សាដែលប្រព្រឹត្តលើពួកគេដែរឬទេ ?

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញអោយឃើញថាស្ត្រីដែលមានបទពិសោធន៍រងគ្រោះនឹងអំពើហិង្សានៅតែប្រឈមមុខទៅនឹងការស្តីបន្ទោសមួយកម្រិតដែរពីសមាជិកមួយចំនួននៅក្នុងសហគមន៍ដូចជាប្រធានសហគមន៍និងអ្នកកាន់កាតព្វកិច្ចខ្លះនៅក្នុងសហគមន៍។
នៅក្នុងបរិមាណនេះ (ទិន្នន័យស្ទង់មតិគ្រួសារ)
ស្ទើរតែពាក់កណ្តាលនៃចំនួនមនុស្សដែលផ្តល់ការសំភាសន៍ (៤៦%) គិតថាស្ត្រីពេលខ្លះគួរតែត្រូវស្តីបន្ទោសខ្លះដែរចំពោះហិង្សាដែលប្តីរបស់ពួកគេប្រព្រឹត្តទៅលើគេ។

### អនុសាសន៍:

នៅពេលស្វែងរកការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សារបស់បុរសលើស្ត្រី អ្វីដែលសំខាន់នោះគឺការផ្លាស់ប្តូរឥរិយាបថនិងអាកប្បកិរិយារបស់មនុស្សប្រុស។
ការស្រាវជ្រាវបានបង្ហាញថាបើទោះបីជាទីកន្លែងមានសុវត្ថិភាពតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធយ៉ាងណាក៏ដោយ
ប្រសិនបើអំពើហិង្សាក្នុងគ្រួសារត្រូវបានគេមើលឃើញថាជារឿងធម្មតា ហើយបុរសនៅតែបន្តយល់ថាមានសិទ្ធបំពានលើរាងកាយរបស់ស្ត្រី ដូចជានៅតាមទីសាធារណៈនៅពេលយប់
នោះអំពើហិង្សាយេនឌ័រនឹងបន្តកើតមានឡើង។
រាល់វិធានការអន្តរាគមន៍ទាំងអស់គួររួមបញ្ចូលគោលបំណងផ្លាស់ប្តូរឥរិយាបថនិងអាកប្បកិរិយាឱ្យជាក់លាក់
និងផ្តល់ការអប់រំនិងសារយ៉ាងមុតមាំលើសេរីភាពនិងសុចរិតភាពផ្លូវភេទរបស់ស្ត្រី។

### ការឆ្លើយតបក្នុងការសម្ភាសន៍: ស្ត្រីពេលខ្លះត្រូវស្តីបន្ទោសប្រសិនបើ:

- "ស្ត្រីនោះលេងល្បែងស៊ីសង។" (ប៉ូលីស)
- "ស្ត្រីម្នាក់នោះដើរតែម្នាក់ឯងនៅពាក់កណ្តាលអាធ្រាត។" (ប៉ូលីស)
- "ពេលខ្លះមកពីការស្លៀកពាក់របស់ស្ត្រី (សិចស៊ីពេកឬខ្លីពេក)" (ស្ត្រីដែលជាប្រធានសហគមន៍)
- "ស្ត្រីខ្លះមិនដឹងតួនាទីរបស់ខ្លួន (ឧទាហរណ៍ ធ្វើម្ហូបឬមើលថែកូន)" (ស្ត្រីដែលជាប្រធានសហគមន៍)
- "ពេលខ្លះម្តាយមិនបានមើលថែកូនស្រីអោយបានល្អ ទើបធ្វើអោយកូនស្រីរបស់ពួកគេខ្លាយជាជនរងគ្រោះក្នុងករណីរំលោភ។" (ស្ត្រីដែលជាប្រធានសហគមន៍)

### ស្ត្រីមិនត្រូវរងការស្តីបន្ទោសទេព្រោះ:

- "យើងមិនអាចស្តីបន្ទោសក្មេងស្រីដែលស្លៀកពាក់ខ្លីទេ។ វាគឺជារាងកាយរបស់នាងផ្ទាល់។" (សមាជិក គណៈកម្មាធិការឃុំដើម្បីស្ត្រីនិងកុមារ)
- "ស្ត្រីមិនត្រូវរងការបន្ទោសដាច់ខាត។ ការរំលោភបំពានផ្លូវកាយលើស្ត្រីគឺតែងតែខុស។" (ស្ត្រីដែលរស់នៅក្នុងតំបន់)
- យើងមិនគួរស្តីបន្ទោសស្ត្រីទេ។ ពីព្រោះនាងគឺជាជនរងគ្រោះ យើងមិនអាចបន្ទោសនាងនោះទេ។ ហើយប្តីរបស់នាងគួរតែមករកនាងហើយសុំទោស ។ (បុរសដែលរស់នៅក្នុងតំបន់)

*ការសិក្សានេះមានការស្ទង់មតិចំនួន 167 គ្រួសារការពិភាក្សាក្រុមចំនួន 6 និងការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន 20 ។ សម្រាប់វិធីសាស្ត្រពេញលេញនិងការរកឃើញ អ្នកអាចរករបាយការណ៍តាមអ៊ីនធឺណែត www.klahaan.org/publications

klahaan · PEOPLE IN NEED CZECH REPUBLIC · UPWD · UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER Cambodia · EUROPEAN UNION